# សុន្ទរកថា អ្នកអគ្គម្ចាស់ ស៊ីសុវត្ថិ តានុវត្តិ អភិបាលរង រាជធានីភ្នំពេញ

## ថ្លែងក្នុងទិវាតំបន់ដីសើមពិភពលោក

## ថ្ងៃទី ០២ កុម្ភៈ ឆ្នាំ ២០០៦

(នៅសួនច្បារជ្រោយចង្វារ)

- សូមក្រាបថ្វាយបង្គំ ព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ
- សូមគោរពឯកឧត្តម តាន់ វុំដ្ឋា រដ្ឋលេខាធិការក្រសួងបរិស្ថាន
- សូមគោរពឯកឧត្តម លោកជំទាវ អស់លោក-លោកស្រី និងភ្ញៀវកិត្តិយសទាំងអស់ជាទីគោរព
- ប្អូនៗនិស្សិត និងសិស្សានុសិស្សទាំងអស់ជាទីស្រឡាញ់រាប់អាន

ថ្ងៃនេះ ជាឱកាសល្អបំផុតដែលរាជធានីភ្នំពេញបានទទួលនូវការរៀបចំទិវាតំបន់ដីសើមពិភពលោកនេះឡើង ជាពិសេសនៅលើទីតាំងសួនច្បារជ្រោយចង្វារ ដែលជាទីតាំងប្រកបដោយសោភ័ណភាពនៃទីក្រុងភ្នំពេញ។ នេះជាលើកទីមួយ ហើយដែលសាលាក្រុងភ្នំពេញបានចូលរួមផ្ទាល់ ក្នុងពិធីទិវាតំបន់ដីសើមពិភពលោកនេះ។ ក្នុងនាមសាលាក្រុងភ្នំពេញ និងក្នុងនាមរូបខ្ញុំផ្ទាល់ ខ្ញុំមានសេចក្តីរីករាយជាអនេកដោយឃើញមានការយកចិត្តទុកដាក់ជួយគាំទ្រពីស្ថាប័ននានា អង្គការសង្គមស៊ីវិល ពិសេសពីសាធារណជន ក្នុងការចូលរួមចំណែកក្នុងកិច្ចការពារនិងថែរក្សាបរិស្ថានរាជធានីភ្នំពេញ ដោយឡែកនោះគឺតំបន់ដីសើមក្នុងរាជធានីភ្នំពេញនេះតែម្តង។ ក្នុងនាមអាជ្ញាធរដែនដី ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅបំផុត និងថ្លែងអំណរគុណក្នុងកិច្ចប្រឹងប្រែងរបស់ឯកឧត្តម អស់លោក លោកស្រី និងជាពិសេសប្អូនៗសិស្សនិងនិស្សិតដែលបានចូលរួមនិងថែរក្សាបរិស្ថានយើង។ ជាពិសេស សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់ក្រសួងបរិស្ថាន និងកម្មវិធីអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាពនូវជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គ (MWBP) ដែលបានខិតខំប្រឹងប្រែងរៀបចំឱ្យមានទិវានេះ កើតឡើង។

ព្រះថេរានុថេរៈ ឯកឧត្តម អស់លោក-លោកស្រី ប្អូនៗនិស្សិត និងសិស្សានុសិស្ស ក្នុងឱកាសនេះផងដែរ សាលាក្រុងភ្នំពេញសូមជំរាបពីការរីកចំរើន និងកិច្ចប្រឹងប្រែងរបស់សាលាក្រុងដែលបានរៀបចំកន្លងមកនេះ គឺការរៀបចំឱ្យមានប្រព័ន្ធនិរន្តរភាពក្នុងការកាត់បន្ថយភាពក្រីក្រក្នុងទីក្រុង ដែលរួមទាំងការរៀបចំប្លង់គោលសំរាប់ទីក្រុង។ ជាគោលការណ៍សាលាក្រុង ធ្វើការអភិវឌ្ឍន៍ទីក្រុង ដោយវិធីសាស្ត្រមានការចូលរួមពីគ្រប់ស្ថាប័ន មន្ទីរ អង្គភាពជំនាញ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន និង ប្រជាពលរដ្ឋគ្រប់លំដាប់ថ្នាក់។ សូមជំរាបជូនថា រាជធានីភ្នំពេញមានផ្ទៃដីសរុប៣៧៥ គម$^{២}$ ចែកជា៧ខ័ណ្ឌ មានប្រជាជនសរុប១ ០៦៣ ៨៥៦ នាក់ មានដង់ស៊ីតេ ២៨៣៦ នាក់/គម$^{២}$ រីឯសំណល់រឹងមានប្រមាណ៩៣០តោន/១ថ្ងៃ។ ប្រជាជនដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រមានប្រមាណ២៥%សំរាប់រាជធានីភ្នំពេញតាមស្ថិតិឆ្នាំ ២០០៤។ នេះជាបញ្ហាប្រឈមមុខដ៏ធ្ងន់ធ្ងររបស់សាលាក្រុងភ្នំពេញក្នុងពេលបច្ចុប្បន្ននេះដែលតំរូវឱ្យមានការរៀបចំ និងអភិវឌ្ឍន៍ទីក្រុង ដើម្បីទទួលបានទាំងគុណភាពបរិស្ថាន សេដ្ឋកិច្ចសង្គម

និងមនុស្សជាតិ ។ល។ ខ្ញុំទទួលស្គាល់ថា តំបន់ដីសើមបានផ្តល់ផលប្រយោជន៍យ៉ាងសន្ធឹកសន្ធាប់ ដោយផ្ទាល់ដូចជា ស្រះចិញ្ចឹមត្រីមានចំនួនកើនឡើងជាលំដាប់ ដែលនៅក្នុងឆ្នាំ ២០០៣ មានចំនួន ៩៧៩ស្រះ និងនៅក្នុងទន្លេមានចំនួន១៨២១កន្លែង ។ បើក្រឡេកមើលចំនួនអ្នកនេសាទមាន១៥៣៧០គ្រួសារ និងមានសហគមន៍នេសាទពីរ ដែលជិតស្មើ១០%នៃប្រជាជន ក្នុងរាជធានីសរុប នេះមិនទាន់គិតដល់អ្នកធ្វើការកែច្នៃ និងធ្វើការងារពាក់ព័ន្ធវិស័យនេះមួយផង ។

ម្យ៉ាងទៀតមានសេវាកម្មជាច្រើនដូចជាប្រព័ន្ធដឹកជញ្ជូនផ្លូវទឹក និងដោយឡែករាជធានីភ្នំពេញ មានរាងជាបាតខ្ទះ ដែលហ៊ុំព័ទ្ធទៅដោយបឹងនានាជាច្រើនដូច ឯកឧត្តម អស់លោក-លោកស្រីជ្រាបស្រាប់ ។ ដូចនេះ បឹង និងត្រពាំងទាំងអស់គឺជាអាងស្តុកទឹក ដែលជួយស្រូបយកបរិមាណទឹកដ៏ច្រើន ដើម្បីការពារទឹកជំនន់ដល់ទីក្រុងភ្នំពេញ និងតំបន់ក្បែរនេះផ្សេងៗទៀត ។ ម្យ៉ាងទៀតបឹងទាំងនេះ ជាអាងប្រព្រឹត្តិកម្មធម្មជាតិ សំរាប់សំណល់រាវ នៅរាជធានីភ្នំពេញផ្ទាល់ ។

សាលាក្រុងភ្នំពេញបានខិតខំរៀបចំទីក្រុងស្អាត គ្មានការបំពុលដល់សុខភាពសាធារណៈ ការរក្សានូវប្រភពទឹកគ្មានការបំពុលក្នុងទីក្រុង ទប់ស្កាត់និងកាត់បន្ថយការបំពុលទឹកនៅប្រភព និង ជំរុញឱ្យមានអាងប្រព្រឹត្តិកម្មសំរាប់សំអាតទឹកសំអុយនិងជាតិពុលចេញពីទីក្រុង ។ បន្ថែមជាងនេះទៅទៀតសាលាក្រុងគ្រប់គ្រងនិងទុកដាក់សំណល់រឹងសំរាមឱ្យមានសុវត្ថិភាពដល់សុខភាពសាធារណៈ បង្ការជាមុននូវសំណល់គ្រោះថ្នាក់ក៏ដូចជា បន្ថយឱ្យបានអប្បបរិមានូវសំណល់រឹងចូលរាជធានីភ្នំពេញ ។ ម្យ៉ាងទៀតសាលាក្រុងគិតគូរផងដែរ ពីការរៀបចំស្ថារ និងកសាងប្រព័ន្ធធារាសាស្ត្រនៅតំបន់កសិកម្មជាយក្រុង ។ ទាំងនេះជាការខិតខំប្រឹងប្រែងរបស់សាលាក្រុង រួមទាំងកិច្ចសហប្រតិបត្តិការពីសំណាក់សាធារណៈជន សង្គមស៊ីវិល និងផ្នែកឯកជន ។

ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ឯកឧត្តម អស់លោក-លោកស្រីទាំងអស់ជាទីគោរព ទោះជាមានការខ្វះខ្នែងយ៉ាងដូចនេះក៏ដោយ ក៏កង្វះខាតនៅតែមានពុំអាចគេចរួច ដែលត្រូវការកិច្ចសហការជាមួយគ្នាផ្ទាល់ដើម្បីដោះស្រាយបញ្ហាអស់ទាំងនេះ ។ ក្នុងនាមសាលាក្រុងភ្នំពេញ និងរូបខ្ញុំផ្ទាល់ សូមប្តេជ្ញាធ្វើឱ្យប្រសើរឡើងនូវទីក្រុងស្អាត ដែលប្រកបដោយសោភ័ណ្ឌភាពនៃតំបន់ដីសើម ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជ័យប្រគេននិងជូនចំពោះគណៈអធិបតី ឯកឧត្តម អស់លោក-លោកស្រី និងបងប្អូនជនរួមជាតិយើងទាំងអស់ សូមបានទទួលនិងប្រកបដោយសេចក្តីសុខចំរើនជាប្រយោជន៍ដើម្បីចូលរួមការពារថែរក្សាបរិស្ថានទីក្រុង និងជាពិសេសតំបន់ដីសើមរាជធានីភ្នំពេញ សំរាប់ជាសោភ័ណ្ឌភាពរបស់ក្រុង ។

**សូមថ្លែងអំណរគុណ និងសូមអរគុណ!**

**ជយោ! ស្មារតីទិវាតំបន់ដីសើមជាតិ ២ កុម្ភៈ ២០០៦**